ANNA & ASSOCIATES
Law Office

# បច្ចុប្បន្នភាពគតិយុត្ត – ឯកសារតម្រូវសម្រាប់ការចុះបញ្ជីកែប្រែ ការរំលាយ និងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម

## ប្រកាសលេខ ១១៧ ព.ណ.ចបព.ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៥ ស្ដីពីការធ្វើសាមញ្ញកម្មនៃការងារចុះបញ្ជីពាណិជ្ជកម្ម របស់ក្រសួងពាណិជ្ជកម្ម

*ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦ – រាជធានីភ្នំពេញ – ព្រះរាជាណាចក្រកម្ពុជា*

កន្លងមក ការកែប្រែ ការរំលាយ និងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្មមានភាពស្មុគស្មាញ ចំណាយពេលយូរ និងថវិការច្រើន ដោយសារនីតិវិធីស្មុគស្មាញ និងប្រព័ន្ធការិយាធិបតេយ្យ។ បើទោះបីជាមានការបង្កើតប្រព័ន្ធ www.registrationservices.gov.kh ក៏ដោយ ក៏តម្រូវការឯកសារមួយចំនួននៅមានភាពស្រពិចស្រពិល និងស្មុគស្មាញតាមបទដ្ឋានគតិយុត្តផ្សេងៗគ្នា។ ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងពាណិជ្ជកម្មបានចេញ **ប្រកាសស្ដីពីការធ្វើសាមញ្ញកម្មនៃការងារចុះបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៥** ក្នុងគោលបំណងកាត់បន្ថយនីតិវិធី និងផ្ដល់ភាពច្បាស់លាស់ដល់ពាណិជ្ជករ។

### ១. ការចុះបញ្ជីកែប្រែសម្រាប់សហគ្រាស និងក្រុមហ៊ុន

រាល់ពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយ ដែលបានចុះបញ្ជីពាណិជ្ជកម្មមានកាតព្វកិច្ចចុះបញ្ជីនូវរាល់ការផ្លាស់ប្ដូរ ឬកែប្រែរបស់សហគ្រាស ឬក្រុមហ៊ុនតាមប្រព័ន្ធស្វ័យប្រវត្តកម្មដែលកំណត់ដោយក្រសួងពាណិជ្ជកម្ម។ សំណុំឯកសារដែលត្រូវបញ្ចូលក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មជាទម្រង់អេឡិចត្រូនិក មានដូចខាងក្រោម៖

**ក. សំណុំឯកសារដែលត្រូវបញ្ចូលក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មជាទម្រង់អេឡិចត្រូនិកសម្រាប់សហគ្រាស និងក្រុមហ៊ុន៖**

- កំណត់ហេតុអង្គប្រជុំ ឬសេចក្ដីសម្រេចរបស់ម្ចាស់ហ៊ុន
- លិខិតស្នើសុំធ្វើការផ្លាស់ប្ដូរកែប្រែ
- ច្បាប់ចម្លងលិខិតគោលការណ៍ចេញពីស្ថាប័នពាក់ព័ន្ធ
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន និងរូបថតទំហំ ៤x៦ ផ្ទៃខាងក្រោយពណ៌សរបស់ម្ចាស់ហ៊ុនថ្មី អភិបាលថ្មី ឬអ្នកតំណាងថ្មីម្នាក់ៗ
- ក្នុងករណីម្ចាស់ហ៊ុនជានីតិបុគ្គល សាមីក្រុមហ៊ុនត្រូវភ្ជាប់ឯកសារដូចខាងក្រោម៖
  - ច្បាប់ចម្លងឯកសារគតិយុត្ត នៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើម (លក្ខន្តិកៈ និងវិញ្ញាបនបត្ររបស់ក្រុមហ៊ុន) និងសេចក្ដីសម្រេចក្នុងការទិញភាគហ៊ុន និងការតែងតាំងអ្នកតំណាង (សម្រាប់ម្ចាស់ហ៊ុនថ្មីជានីតិបុគ្គល) បញ្ជាក់ដោយសារការីនៃព្រះរាជាណាចក្រកម្ពុជា ឬស្ថានទូត ឬស្ថានកុងស៊ុល ឬសភាពាណិជ្ជកម្ម បរទេសដែលទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម
  - សេចក្ដីសម្រេចក្នុងការផ្ទេរ ឬការលក់ភាគហ៊ុន ដោយមានការបញ្ជាក់ដោយសារការីនៃព្រះរាជាណាចក្រកម្ពុជា ឬស្ថានទូត ឬស្ថានកុងស៊ុល ឬសភាពាណិជ្ជកម្មបរទេសដែលទទួលស្គាល់ដោយក្រសួង



*__ការបដិសេធ:__ ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្ដល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្ដោតសំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្ដល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*

ពាណិជ្ជកម្ម ឬតាមរយៈការស្នើសុំបំពេញនីតិវិធីផ្ទេរ ឬលក់ភាគហ៊ុនតាមប្រព័ន្ធអនឡាញ នៅចំពោះមុខមន្ត្រីចុះបញ្ជីនៃក្រសួងពាណិជ្ជកម្ម (សម្រាប់ការផ្ទេរ ឬលក់ភាគហ៊ុនម្ចាស់ហ៊ុនជានីតិបុគ្គល)

- ការពិនិត្យសារតារូបវន្តបុគ្គលសម្រាប់ម្ចាស់ហ៊ុន ឬអភិបាលថ្មី សំដៅជានាការប្រឆាំងការសម្អាតប្រាក់តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

**ខ. សំណុំឯកសារដែលត្រូវតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម៖**

ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចុះបញ្ជីកែប្រែតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ក្រុមហ៊ុន ត្រូវយកឯកសារច្បាប់ដើមមកតម្កល់នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មមានដូចខាងក្រោម៖

- លិខិតស្នើសុំធ្វើការផ្លាស់ប្តូរកែប្រែច្បាប់ដើម ចំនួន (២ ច្បាប់)
- កំណត់ហេតុអង្គប្រជុំ ឬសេចក្តីសម្រេចរបស់ម្ចាស់ហ៊ុនច្បាប់ដើម ចំនួន (២ ច្បាប់)
- ក្នុងករណីម្ចាស់ហ៊ុនជានីតិបុគ្គល សាមីក្រុមហ៊ុនត្រូវតម្កល់ឯកសារដូចខាងក្រោម៖
  - ច្បាប់ចម្លងឯកសារគតិយុត្ត នៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើម (លក្ខន្តិកៈ និងវិញ្ញាបនបត្ររបស់ក្រុមហ៊ុន) និងសេចក្តីសម្រេចក្នុងការទិញភាគហ៊ុន និងការតែងតាំងអ្នកតំណាង (សម្រាប់ម្ចាស់ហ៊ុនថ្មីជានីតិបុគ្គល) បញ្ជាក់ដោយសារការីនៃព្រះរាជាណាចក្រកម្ពុជា ឬស្ថានទូត ឬស្ថានកុងស៊ុល ឬសភាពាណិជ្ជកម្ម បរទេស ដែលទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម
  - សេចក្តីសម្រេចក្នុងការផ្ទេរ ឬការលក់ភាគហ៊ុន បញ្ជាក់ដោយសារការីនៃព្រះរាជាណាចក្រកម្ពុជា ឬស្ថានទូត ឬស្ថានកុងស៊ុល ឬសភាពាណិជ្ជកម្មបរទេស ដែលទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម ឬតាមរយៈការស្នើសុំ បំពេញនីតិវិធីផ្ទេរ ឬលក់ភាគហ៊ុនតាមប្រព័ន្ធអនឡាញ នៅចំពោះមុខមន្ត្រីចុះបញ្ជីនៃក្រសួងពាណិជ្ជកម្ម (សម្រាប់ការផ្ទេរ ឬលក់ភាគហ៊ុនម្ចាស់ហ៊ុនជានីតិបុគ្គល)
- លក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន (ក្នុងករណីមានការកែប្រែ) ចំនួន (២ ច្បាប់)។

## ២. ការរំលាយ និងការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម

ចំពោះក្រុមហ៊ុន សហគ្រាស ដែលបានបំពេញកាតព្វកិច្ចបំណុលពន្ធតាមរយៈសវនកម្មជម្រះបញ្ជីពីអគ្គនាយកដ្ឋានពន្ធដារ ហើយទទួលបានលិខិតបញ្ជាក់ស្តីពីការបិទក្រុមហ៊ុនជាស្ថាពររួចរាល់។ ក្រុមហ៊ុន សហគ្រាសអាចស្នើសុំបន្តនីតិវិធីរំលាយ និងលុបឈ្មោះក្រុមហ៊ុន សហគ្រាស មកក្រសួងពាណិជ្ជកម្មបាន ពីគ្រប់ទីកន្លែងតាមរយៈគេហទំព័រ www.businessregistration.moc.gov.kh ។

**ក. សំណុំឯកសារស្តីពីសំណើសុំប្រកាសពីបំណងក្នុងការជម្រះបញ្ជី ឬរំលាយក្រុមហ៊ុន សហគ្រាស មានដូចខាងក្រោម៖**

- សំណើស្នើសុំ ចំនួន (១ ច្បាប់)
- សេចក្តីសម្រេចសមូហភាពរបស់ម្ចាស់ហ៊ុន ចំនួន (១ ច្បាប់)
- លិខិតបញ្ជាក់ស្ថានភាពសារពើពន្ធរបស់ក្រុមហ៊ុន ចំនួន (១ ច្បាប់)
- លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ (គិតត្រឹមកាលបរិច្ឆេទបញ្ឈប់អាជីវកម្មជាស្ថាពរ) ចំនួន (១ ច្បាប់)។



*__ការបដិសេធ:__ ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោតសំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*

ANNA & ASSOCIATES
Law Office

ខ. សំណុំឯកសារចុះបញ្ជីលើការរំលាយ និងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម មានដូចខាងក្រោម៖

- សំណើស្នើសុំ ចំនួន (១ ច្បាប់)
- សេចក្តីសម្រេចសមូហភាពរបស់ម្ចាស់ហ៊ុន ចំនួន (១ ច្បាប់)
- លិខិតបញ្ជាក់ស្ថានភាពសារពើពន្ធរបស់ក្រុមហ៊ុន ចំនួន (១ ច្បាប់)
- របាយការណ៍ស្តីពីការជម្រះបញ្ជី រំលាយក្រុមហ៊ុន ចំនួន (១ ច្បាប់)
- វិក្កយបត្របង់ពន្ធបន្ថែម (ប្រសិនបើមានការពិន័យនៅចំណុចទី៤) ចំនួន (១ ច្បាប់)
- របាយការណ៍បិទបញ្ជីប្រចាំឆ្នាំ (ឆ្នាំចុងក្រោយ) ចំនួន (១ ច្បាប់)
- លិខិតតែងតាំងសវនករ ចំនួន (១ ច្បាប់)
  * សវនករ ត្រូវតែជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលទទួលបានអាជ្ញាប័ណ្ណគណនេយ្យ និង/ឬសវនកម្ម ពីនិយ័តករគណនេយ្យនិងសវនកម្មនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនសវនករ ចំនួន (១ ច្បាប់)។

<u>កំណត់ចំណាំ</u>៖ ពាណិជ្ជករ ម្ចាស់ហ៊ុន ឬអភិបាលត្រូវធានាអះអាងចំពោះរាល់ព័ត៌មាន សម្រាប់ការស្នើសុំកែប្រែ រំលាយ និងលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ឯកសារតម្រូវដែលខ្លួនបានបំពេញ និងបញ្ចូលតាមថ្នាលបច្ចេកវិទ្យាព័ត៌មានជាទម្រង់អេឡិចត្រូនិក រួមបញ្ចូលទាំងហត្ថលេខាឌីជីថល ដែលអនុលោមស្របតាមបទប្បញ្ញត្តិជាធរមាន (ប្រសិនបើមាន) ជាពិតជាព័ត៌មាន ឯកសារត្រឹមត្រូវ និង មិនក្លែងបន្លំ។

**ទំនាក់ទំនងមកកាន់៖**

**ការិយាល័យមេធាវី អេណា និងសហការី**

**គេហទំព័រ**: www.anna-associates.com

**អ៊ីម៉ែល**: info@anna-associates.com

**លេខទូរស័ព្ទ**: (+៨៥៥) ៩៩ ៨៨៨ ៧៣៧

**អាសយដ្ឋាន៖**

**អាសយដ្ឋានការិយាល័យ**: អាគារ K Plaza លេខ២៣៤ ជាន់ទី៧ មហាវិថីម៉ៅសេទុង សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា



***<u>ការបដិសេធ:</u>*** *ព័ត៌មានដែលបានរៀបរៀងនៅក្នុងព្រឹត្តិបត្រគតិយុត្តរបស់អេណា គឺក្នុងគោលបំណងសម្រាប់ផ្តល់ជាព័ត៌មានតែប៉ុណ្ណោះ និងមិនផ្តោតសំខាន់ ទៅលើការប្រឹក្សាយោបល់ផ្នែកច្បាប់ឡើយ។ សូមធ្វើការកត់សម្គាល់ថា ការប្រឹក្សាផ្នែកច្បាប់ត្រូវធ្វើឡើង និងផ្តល់ជូនដោយមេធាវីប្រកបដោយសមត្ថភាព ព្រមទាំងគុណភាព ដែលធ្វើការប្រឹក្សាយោបល់ទៅលើគ្រប់ស្ថានភាពទាំងអស់។*